ខិត្តប័ណ្ណព័ត៌មានអំពីថ្នាំបង្ការ

# ថ្នាំបង្ការជម្ងឺ Tdap
## អ្វីដែលអ្នកត្រូវដឹង

(ជម្ងឺតេតណូស ខាន់ស្លាក់ និងក្អកមាន់)

Many Vaccine Information Statements are available in Spanish and other languages. See www.immunize.org/vis

ខិត្តប័ណ្ណព័ត៌មានស្តីអំពីថ្នាំបង្ការមួយចំនួន បានបោះពុម្ពផ្សាយជាភាសាអេស្ប៉ាញ និងភាសាផ្សេងៗទៀត ។ សូមទស្សនាគេហទំព័រ www.immunize.org/vis

## 1 | ហេតុអ្វីអ្នកត្រូវចាក់ថ្នាំបង្ការ?

ជម្ងឺតេតណូស ខាន់ស្លាក់ និងក្អកមាន់ អាចជាជម្ងឺធ្ងន់ធ្ងរមួយ សូម្បីតែក្មេងជំទង់ និងមនុស្សចាស់ក៏អាចកើតជម្ងឺនេះធ្ងន់ធ្ងរបានដែរ ។ ថ្នាំបង្ការជម្ងឺTdap អាចការពារពួកយើងមិនឲ្យកើតជម្ងឺទាំងបីមុខនេះបាន ។

ជម្ងឺតេតាណូស (ជម្ងឺរឹងថ្គាម) វាបណ្តាលឲ្យសាច់ដុំឈឺឡើងតឹង និងរឹងពិបាកបត់ចុះឡើងជាធម្មតាវាកើតឡើងចំពោះសាច់ដុំពេញរាងកាយ។

- វាអាចនាំឲ្យកើតការតឹងសាច់ដុំក្បាល និងក ដែលធ្វើឲ្យអ្នកមិនអាចហារមាត់រួច មិនអាចលេបអ្វីចូលបាន ឬពេលខ្លះសូម្បីតែដកដង្ហើមក៏ដកមិនរួចដែរ ។ ជម្ងឺតេតាណូសអាចសម្លាប់ជីវិតមនុស្ស 1 ក្នុងចំណោម 5 នាក់ដែលកើតជម្ងឺនេះ ។

រោគខាន់ស្លាក់ អាចបង្កឲ្យសាច់ក្នុងបំពង់កផ្នែកខាងក្រោយឡើងប៉ោងហើយមានភាពក្រាស់ ។

- សាច់ប៉ោងនេះ វាអាចធ្វើឲ្យពិបាកដកដង្ហើម កម្រើកមិនបាន គាំងបេះដូង និងធ្វើឲ្យស្លាប់បាន ។

ជម្ងឺក្អកខ្លាំង (ក្អកមាន់) វាធ្វើឲ្យមានការក្អកខ្លាំង ដែលអាចនាំឲ្យពិបាកដកដង្ហើម ក្អួត និងរំខានដល់ដំណេក ។

- ជម្ងឺនេះក៏អាចនាំឲ្យអ្នកជម្ងឺស្រកទម្ងន់ មានអារម្មណ៍មិនសុខស្រួល និងស្រាំឆ្អឹងជំនី ។ មានមនុស្សពេញវ័យរហូតដល់ទៅ 2 នាក់ ក្នុងចំណោមអ្នកជម្ងឺ 100 នាក់ និងចំនួន 5 នាក់ ក្នុងចំណោមមនុស្សចាស់ 100 នាក់ ដែលកើតជម្ងឺក្អកមាន់ត្រូវសម្រាកពេទ្យ ឬកើតជម្ងឺផ្សេងៗទៀតដូចជាជម្ងឺហើមសួត ឬអាចបណ្តាលឲ្យអ្នកជម្ងឺស្លាប់បាត់បង់ជីវិតផងដែរ ។

ជម្ងឺទាំងនេះ កើតឡើងបណ្តាលមកពីមេរោគបាក់តេរី ។ រោគខាន់ស្លាក់ និងជម្ងឺក្អកមាន់ វាឆ្លងរាលដាលពីមនុស្សម្នាក់ទៅមនុស្សម្នាក់ តាមរយៈការក្អក ឬការកណ្តាស់ ។ ជម្ងឺតេតាណូស ឆ្លងចូលក្នុងរាងកាយមនុស្សតាមរយៈស្នាមរបួស ស្នាមដាច់ស្បែក ឬក៏ដំបៅ ។

នៅមុនពេលមានថ្នាំបង្ការ នៅសហរដ្ឋអាមេរិក មានពលរដ្ឋកើតរោគខាន់ស្លាក់ ឬជម្ងឺក្អកមាន់ រហូតដល់ទៅ 200,000 ករណីក្នុងមួយឆ្នាំ ហើយមានអ្នកកើតជម្ងឺតេតាណូសរាប់រយករណី ។ ចាប់តាំងពីមានការចាក់ថ្នាំបង្ការ ជម្ងឺតេតាណូស និងរោគខាន់ស្លាក់ បានធ្លាក់ចុះរហូតដល់ 99% ហើយជម្ងឺក្អកមាន់បានធ្លាក់ចុះរហូតដល់ 80% ។

## 2 | ថ្នាំបង្ការជម្ងឺ Tdap

ថ្នាំបង្ការជម្ងឺ Tdap អាចជួយការពារមនុស្សពេញវ័យ និងមនុស្សចាស់មិនឲ្យកើតជម្ងឺតេតាណូស រោគខាន់ស្លាក់ និងជម្ងឺក្អកមាន់ ។ មួយដូសនៃថ្នាំបង្ការជម្ងឺ Tdap ត្រូវបានចាក់ជាប្រចាំពេលក្មេងមានអាយុ 11 ឬ 12 ឆ្នាំ ។ ចំពោះអ្នកណាដែលមិនបានចាក់ថ្នាំបង្ការ Tdap នៅក្នុងវ័យនេះ ត្រូវទៅឲ្យពេទ្យចាក់ឲ្យបានលឿនតាមដែលអាចធ្វើទៅបាន ។

ថ្នាំបង្ការ Tdap មានភាពសំខាន់ពិសេសចំពោះអ្នក ថែទាំសុខភាពអាជីព និងអ្នកទាំងឡាយណាដែលមានទំនាក់ទំនងជិតជាមួយនឹងទារក ដែលមានអាយុក្រោម 12 ខែ ។

ស្ត្រីមានផ្ទៃពោះ ត្រូវទទួលការចាក់ថ្នាំបង្ការ Tdap ឲ្យបានមួយដូស ក្នុងពេលមានគភ៌មួយលើកៗ ដើម្បីជួយការពារទារកដែលទើបនឹងកើតពីជម្ងឺក្អកមាន់ ។ ទារកតូចប្រឈមមុខខ្លាំងបំផុតពីការកើតជម្ងឺក្អកមាន់ធ្ងន់ធ្ងរ ដែលឈានទៅរកការកើតជម្ងឺផ្សេងៗ ដោយមានការគម្រាមកំហែងដល់អាយុជីវិត ។

ថ្នាំបង្ការដែលមានភាពស្រដៀងគ្នានេះ មួយប្រភេទ ដែលហៅថាថ្នាំបង្ការ Td ជាថ្នាំការពារមិនឲ្យកើតជម្ងឺ តេតាណូស និងរោគខាន់ស្លាក់ គឺមិនអាចការពារជម្ងឺក្អកមាន់បានទេ ។ ថ្នាំបង្ការ Td ដែលត្រូវចាក់បន្ថែម ត្រូវចាក់ក្នុងរៀងរាល់ 10 ឆ្នាំម្តង ។ ថ្នាំបង្ការ Tdap អាចយកមកចាក់បន្ថែមបានដែរ ប្រសិនបើអ្នកនៅមិនទាន់ បានទទួលថ្នាំបង្ការនេះមួយដូសទេនោះ ។ ថ្នាំបង្ការ Tdap ក៏អាចចាក់បានដែរ បន្ទាប់ពីអ្នកមានរបួស ឬការរលាកធ្ងន់ធ្ងរ ដើម្បីបង្ការការឆ្លងជម្ងឺតេតាណូស ។

គ្រូពេទ្យរបស់អ្នកអាចផ្តល់ព័ត៌មានបន្ថែមដល់អ្នក ។

ថ្នាំបង្ការ Tdap អាចចាក់បានយ៉ាងមានសុវត្ថិភាព ក្នុងពេលតែមួយជាមួយនឹងថ្នាំបង្ការដទៃទៀតដែរ ។

## 3 | មនុស្សខ្លះមិនអាចចាក់ថ្នាំបង្ការប្រភេទនេះបានទេ

- បើអ្នកធ្លាប់មានការប្រតិកម្មថ្នាំធ្ងន់ធ្ងរគម្រាមកំហែងដល់ជីវិត ក្រោយពេលចាក់ថ្នាំបង្ការជម្ងឺតេតាណូស រោគខាន់ស្លាក់ ឬជម្ងឺក្អកមាន់ ចំនួនមួយដូស ឬ ប្រសិនបើអ្នកមានប្រតិកម្មធ្ងន់ធ្ងរ ចំពោះផ្នែកណាមួយនៃថ្នាំបង្ការនេះ អ្នកមិនត្រូវចាក់ថ្នាំបង្ការ Tdap ឡើយ ។ ត្រូវប្រាប់គ្រូពេទ្យរបស់អ្នកឲ្យបានដឹង ប្រសិនបើអ្នក មានប្រតិកម្មធ្ងន់ធ្ងរណាមួយកើតឡើង ។
- បើអ្នកបាត់ស្មារតី ឬប្រកាច់ក្នុងរយៈពេលយូរ ឬប្រកាច់ច្រើនដងក្នុងរវាង 7 ថ្ងៃ ក្រោយពេលអ្នកបានទទួលថ្នាំបង្ការ DTP ឬ DTaP មួយដូសពេលនៅ ជាកុមារភាព អ្នកមិនត្រូវចាក់ថ្នាំបង្ការ Tdap ឡើយ លើកលែងតែការប្រកាច់ខាងលើត្រូវរកឃើញថាបណ្តាលពីមូលហេតុផ្សេង ។ ករណីនេះ អ្នកនៅតែអាចចាក់ថ្នាំបង្ការ Td បាន ។
- សូមពិភាក្សាជាមួយគ្រូពេទ្យរបស់អ្នក ប្រសិនបើអ្នក ៖
  - កើតជម្ងឺស្កន់ ឬជម្ងឺដទៃទៀតពាក់ព័ន្ធនឹងប្រព័ន្ធសសៃប្រសាទ
  - ធ្លាប់ឈឺចាប់ធ្ងន់ធ្ងរ ឬហើមខ្លាំង ក្រោយពេលអ្នកចាក់ថ្នាំបង្ការណាមួយ ដែលមានជាតិថ្នាំបង្ការរោគខាន់ស្លាក់ ជម្ងឺតេតាណូស ឬជម្ងឺក្អកមាន់
  - ធ្លាប់កើតជម្ងឺ Guillain-Barré Syndrome (GBS-ជម្ងឺប្រព័ន្ធសសៃប្រសាទ)
  - មិនស្រួលខ្លួន ក្នុងថ្ងៃដែលត្រូវចាក់ថ្នាំបង្ការ ។



U.S. Department of Health and Human Services
Centers for Disease Control and Prevention

## 4 | ហានិភ័យបណ្តាលពីការចាក់ថ្នាំបង្ការ

មានឱសថជាច្រើន ដោយរួមទាំងថ្នាំបង្ការ គឺតែងតែមានឱកាសចំពោះផលប៉ះពាល់ ។ ផលប៉ះពាល់ទាំងនេះ ជាធម្មតាមានភាពស្រាល ហើយតែងតែបាត់ទៅវិញ ដោយខ្លួនឯង តែប្រតិកម្មធ្ងន់ធ្ងរក៏អាចកើតឡើងបានផងដែរ ។

គ្រោះអាសន្នចំពោះការងងឹតមុខដួល អាចកើតមានបន្ទាប់ក្រោយការចាក់ថ្នាំបង្ការរួច ដែលនាំឲ្យមានរបួសស្នាម ពីការដួល ។ ការអង្គុយ ឬដេកចំនួនប្រហែលជា 15 នាទី អាចជួយការពារពីការងងិតមុខដួលបាន ។ សូមប្រាប់ឲ្យគ្រូពេទ្យអ្នកបានដឹង បើអ្នកមានអារម្មណ៍វិលមុខ ឈឺក្បាលតិចៗ ឬមានភាពស្រវាំងភ្នែក ឬហ៊ុំងត្រចៀក ។

បញ្ហាក្នុងកម្រិតស្រាល បន្ទាប់ពីការចាក់ថ្នាំបង្ការ ជម្ងឺ Tdap

(វាមិនបង្កការរំខានរហូតដល់មិនអាចឲ្យអ្នកធ្វើអ្វីបានឡើយ)

- ឈឺត្រង់បរិវេណចាក់ម្ជុលចូលក្នុងសាច់ (កើតឡើងប្រហែលជា 3 នាក់ ក្នុងចំណោមមនុស្សពេញវ័យ 4 នាក់ ឬ 2 នាក់ ក្នុងចំណោមមនុស្សចាស់ 3 នាក់)
- ការឡើងក្រហម ឬការហើម ត្រង់បរិវេណចាក់ម្ជុលចូលក្នុងសាច់ (កើតឡើងប្រហែលជា 1 នាក់ ក្នុងចំណោមមនុស្ស 5 នាក់)
- គ្រុនក្តៅតិចតួច ដែលអាចឡើងកំដៅដល់ 100.4°F (មានរហូតដល់ទៅប្រហែលជា 1 នាក់ ក្នុងចំណោមមនុស្សពេញវ័យ 25 នាក់ ឬមានប្រហែលជា 1 នាក់ ក្នុងចំណោមមនុស្សចាស់ 100 នាក់)
- ឈឺក្បាល (ប្រហែលជា 3 នាក់ ឬ 4 នាក់ ក្នុងចំណោមមនុស្ស 10 នាក់)
- ភាពល្ហិតល្ហៃ (ប្រហែលជា 1 នាក់ ក្នុងចំណោមមនុស្ស 3 ឬ 4 នាក់)
- ភាពចង់ក្អួត ការក្អួត រាគរូស ឈឺក្នុងពោះ (មានរហូតដល់ទៅ 1 នាក់ ក្នុងចំណោមមនុស្សពេញវ័យ 4 នាក់ ឬ 1 នាក់ក្នុងចំណោមមនុស្សចាស់ 10 នាក់)
- រងារញាក់ ឈឺពេញរាងកាយ ឈឺសន្លាក់ ឡើងកន្ទួលស្បែក ហើមក្រពេញ (មិនធម្មតា)

បញ្ហាមកម្រិតមធ្យម កើតឡើងបន្ទាប់ពីការចាក់ថ្នាំបង្ការជម្ងឺ Tdap

(បង្កការរំខានចំពោះការធ្វើអ្វីៗ តែមិនចាំបាច់ព្យាបាលឡើយ)

- ឈឺត្រង់បរិវេណចាក់ម្ជុលចូលក្នុងសាច់ (ប្រហែលជា 1 នាក់ ក្នុងចំណោមមនុស្សពេញវ័យ 5 នាក់ ឬ 1 នាក់ ក្នុងចំណោមមនុស្សចាស់ 100 នាក់)
- ការឡើងកន្ទួលក្រហម ឬហើមត្រង់បរិវាណចាក់ម្ជុលចូលក្នុងសាច់ (មានរហូតដល់ទៅ 1 នាក់ ក្នុងចំណោមមនុស្សពេញវ័យ 16 នាក់ ឬ 1 នាក់ ក្នុងចំណោមមនុស្សចាស់ 25 នាក់)
- គ្រុនក្តៅ ដែលឡើងកំដៅលើសពី 102°F (ប្រហែលជា 1 នាក់ក្នុងចំណោមមនុស្សពេញវ័យ 100 នាក់ ឬ 1 នាក់ ក្នុងចំណោមមនុស្សចាស់ 250 នាក់)
- ឈឺក្បាល (ប្រហែលជា 3 នាក់ក្នុងចំណោមមនុស្សពេញវ័យ 20 នាក់ ឬ 1 នាក់ ក្នុងចំណោមមនុស្សចាស់ 10 នាក់)
- ភាពចង់ក្អួត ការក្អួត រាគរូស ឈឺក្នុងពោះ (មានរហូតដល់ទៅ 1 ឬ 3 នាក់ ក្នុងចំណោមមនុស្ស 100 នាក់)
- ហើមដៃទាំងមូល ត្រង់បរិវេណចាក់ម្ជុលចូលក្នុងសាច់ (មានរហូតដល់ទៅប្រហែលជា 3 នាក់ ក្នុងចំណោមមនុស្ស 100 នាក់) ។

បញ្ហាធ្ងន់ធ្ងរ បន្ទាប់ពីការចាក់ថ្នាំបង្ការ Tdap

(មិនអាចធ្វើអ្វីៗជាធម្មតាបាន តម្រូវឲ្យមានការព្យាបាល)

- ហើម ឈឺខ្លាំង ចេញឈាម និងឡើងកន្ទួលក្រហម ត្រង់ដៃដែលចាក់ម្ជុលចូលក្នុងសាច់ (ករណីកម្រកើតមាន) ។

ប្រតិកម្មក្នុងកម្រិតធ្ងន់ធ្ងរ អាចកើតឡើងបន្ទាប់ពីការចាក់ថ្នាំបង្ការណាមួយ (អាចកើតមានតិចជាង 1 ក្នុងការចាក់មួយលានដូស) ។

DCH-1281CA AUTH: P. H. S., Act 42, Sect. 2126.

## 5 | តើត្រូវធ្វើដូចម្តេចប្រសិនបើមានករណីប្រតិកម្មធ្ងន់ធ្ងរកើតឡើង?

តើខ្ញុំត្រូវរកមើលអ្វីខ្លះ?

- ត្រូវរកមើលចំពោះអ្វីដែលធ្វើឲ្យអ្នកព្រួយបារម្ភ ដូចជាសញ្ញានានានៃប្រតិកម្មធ្ងន់ធ្ងរ គ្រុនក្តៅខ្លាំង ឬអ្នកជម្ងឺប្តូរអាកប្បកិរិយា ។

  សញ្ញានានានៃប្រតិកម្មធ្ងន់ធ្ងរ អាចមានរួមបញ្ចូលនូវការចេញកន្ទាលត្រអាក ហើមមុខ និងបំពង់ក ពិបាកដកដង្ហើម បេះដូងដើរញាប់ វិលមុខ និងចុះខ្សោយកម្លាំង ។ អ្វីៗទាំងនេះ អាចកើតឡើងចំនួនពីរបីនាទី ដល់ពីរបីម៉ោង ក្រោយពីការចាក់ថ្នាំបង្ការរួច ។

តើខ្ញុំត្រូវធ្វើអ្វីខ្លះ?

- ប្រសិនបើអ្នកគិតថាវាគឺជាប្រតិកម្មធ្ងន់ធ្ងរ ឬគ្រោះអាសន្នផ្សេងៗទៀត ដែលអ្នកមិនអាចចាំបាន សូមហៅទូរស័ព្ទមកលេខ 9-1-1 ឬនាំអ្នកជម្ងឺមកកាន់មន្ទីរពេទ្យដែលនៅជិតលោកអ្នកជាទីបំផុត ។ បើមិនដូច្នេះទេសូមហៅទូរស័ព្ទមកកាន់គ្រូពេទ្យរបស់អ្នក ។
- បន្ទាប់មក អ្នកត្រូវរាយការណ៍អំពីប្រតិកម្មនេះ ទៅកាន់ Vaccine Adverse Event Reporting System (VAERS-ប្រព័ន្ធរាយការណ៍អំពីប្រតិកម្មពីការចាក់ថ្នាំបង្ការ) ។ គ្រូពេទ្យរបស់អ្នកអាចរាយការណ៍អំពីហេតុការណ៍នេះដែរ ឬក៏អ្នកអាចធ្វើឡើងដោយខ្លួនឯង តាមរយៈគេហទំព័ររបស់ VAERS ដែលមានអាសយដ្ឋាន www.vaers.hhs.gov ឬដោយការហៅទូរស័ព្ទទៅកាន់លេខ 1-800-822-7967 ។

VAERS គឺគ្រាន់តែជាកន្លែងដែលអ្នកត្រូវរាយការណ៍អំពីប្រតិកម្មថ្នាំ ។ ទីនេះមិនមែនជាកន្លែងសម្រាប់ផ្តល់ដំបូន្មានវេជ្ជសាស្ត្រឡើយ ។

## 6 | តើត្រូវធ្វើដូចម្តេចប្រសិនបើមានករណីប្រតិកម្មធ្ងន់ធ្ងរកើតឡើង?

National Vaccine Injury Compensation Program (VICP-កម្មវិធីជាតិផ្តល់សំណងអំពីរបួសស្នាមបណ្តាលពីថ្នាំបង្ការ) គឺជាកម្មវិធីរបស់រដ្ឋាភិបាលសហព័ន្ធ ដែលត្រូវបានបង្កើតឡើង ដើម្បីផ្តល់សំណងដល់ពលរដ្ឋ ដែលអាចរងរបួសបណ្តាលពីថ្នាំបង្ការជម្ងឺណាមួយ ។

ពលរដ្ឋណាដែលមានការជឿជាក់ថា ខ្លួនបានទទួលការរងរបួសដែលអាចបណ្តាលពីថ្នាំបង្ការជម្ងឺ អាចសិក្សាអំពីកម្មវិធីនេះ និងអាចដាក់ពាក្យប្តឹងទារសំណង ដោយការហៅទូរស័ព្ទមកកាន់លេខ 1-800-338-2382 ឬទស្សនាគេហទំព័រ VICP ដែលមានអាសយដ្ឋាន www.hrsa.gov/vaccinecompensation ។

## 7 | តើខ្ញុំអាចបានទទួលព័ត៌មានបន្ថែមដោយរបៀបណា?

- សួរគ្រូពេទ្យរបស់អ្នក ។
- ហៅទូរស័ព្ទមកជួបជាមួយនឹងនាយកដ្ឋានសុខភាពប្រចាំមូលដ្ឋាន ឬប្រចាំរដ្ឋរបស់អ្នក ។
- ទំនាក់ទំនងជាមួយនឹង Centers for Disease Control and Prevention (CDC-មជ្ឈមណ្ឌលគ្រប់គ្រង និងបង្ការជម្ងឺ) ៖
  - ហៅមកលេខ 1-800-232-4636 (1-800-CDC-INFO) ឬ
  - ទស្សនាគេហទំព័ររបស់ CDC ដែលមានអាសយដ្ឋាន www.cdc.gov/vaccines

Vaccine Information Statement (Interim)

**Tdap Vaccine**

Cambodian

2/24/2015

42 U.S.C. § 300aa-26

Translation provided by the California Department of Public Health

Office Use Only

ដើម្បីអនុញ្ញាតឲ្យអ្នកផ្តល់ការព្យាបាលសុខភាពស្នើសុំនូវពត៌មានអំពីការចាក់ថ្នាំបង្ការរោគពេញលក្ខណត្រឹមត្រូវ, ការពិនិត្យមើលនៃការចាក់ថ្នាំបង្ការរោគ ហើយនិងការតម្រូវដាក់ពេលវេលា សំរាប់ចាក់ថ្នាំបង្ការរោគនៅអនាគត, ពត៌មានអំពីការចាក់បង្ការរោគនឹងផ្ញើទៅមន្ទីរ Michigan Care Improvement Registry ។ បុគ្គលទាំងឡាយមានសិទ្ធិស្នើសុំអោយអ្នកផ្តល់ការព្យាបាលសុខ ភាពមិនអោយបញ្ជូនពត៌មានអំពីការចាក់ថ្នាំបង្ការរោគនេះទៅឲ្យកន្លែងទុកសំណុំរឿងបាន។